ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

លេខ : 1892........... បទ [illegible]

# សារាចរណែនាំ

## ស្ដីពីវិធានការណ៍ទប់ស្កាត់ការធ្វើចរាចរគ្រឿងញៀន តាមរយៈប្រៃសណីយ៍

ក្នុងរយៈពេលកន្លងមកនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សង្កេតឃើញថា : មានជនខិលខូចបានផ្ដើមធ្វើចរាចរគ្រឿងញៀនចូល-ចេញនិងឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា តាមរយៈសេវាប្រៃសណីយ៍ ករណីនេះចេះតែកើតមានឡើងជាបន្តបន្ទាប់គួរឱ្យកត់សំគាល់ ។ រីឯក្រសួងមានសមត្ថកិច្ចកម្ពុជា (អាជ្ញាធរប្រឆាំងគ្រឿងញៀនកម្ពុជា) បានប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់និងមានវិធានការចាប់បានជាបន្តបន្ទាប់ ។

ដើម្បីចូលរួមជាមួយអាជ្ញាធរប្រឆាំងគ្រឿងញៀនកម្ពុជាក្នុងសកម្មភាពដ៏អាក្រក់ខាងលើនេះ កន្លងមកក្រសួងបានធ្វើសារាចរណែនាំស្ដីពីការត្រួតពិនិត្យអន្ដរវត្ថុផ្ញើតាមប្រៃសណីយ៍ *លេខ ១៧៤៩ បទ.ប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៣* រួចមកហើយ ។ ដូច្នេះដើម្បីជាការក្រើនរំឭកម្ដងទៀត ក្រសួងសូមធ្វើការណែនាំដល់លោកប្រធាននាយកដ្ឋានប្រៃសណីយ៍ លោក-លោកស្រី ប្រធានមន្ទីរ ប.ទ គ្រប់ខេត្ត-ក្រុង ទាំងអស់មានវិធាន-ការណ៍ប្រុងប្រយ័ត្នជាក់ស្ដែងជាបន្ថែមដូចតទៅ :

**<u>ការទទួលបញ្ញើផ្ញើ ជាលិខិត</u> :**

- ត្រូវណែនាំឱ្យអតិថិជនសរសេរអាស័យដ្ឋាន អ្នកផ្ញើ និង អ្នកទទួលឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងច្បាស់លាស់ ។

**<u>ការទទួលបញ្ញើផ្ញើចេញ ជាប្រភេទកញ្ចប់</u> :**

- អ្នកផ្ញើត្រូវវេចខ្ចប់នៅចំពោះមុខភ្នាក់ងារប្រៃសណីយ៍ និងសមត្ថកិច្ចគយ ។
- តម្រូវឱ្យអ្នកផ្ញើសរសេរអាស័យដ្ឋាន អ្នកផ្ញើនិងអ្នកទទួលគ្រប់គ្រាន់ច្បាស់លាស់និងត្រឹមត្រូវ ។

**<u>ការចែកបញ្ញើជាកញ្ចប់ មកដល់</u> :**

- បញ្ញើប្រភេទជាកញ្ចប់ត្រូវធ្វើលិខិតអញ្ជើញអតិថិជនឱ្យមកបើក និង ត្រួតពិនិត្យអន្ដរវត្ថុនៅចំពោះមុខភ្នាក់ងារគយ ។
- គ្រប់បញ្ជីទទួលបញ្ញើផ្ញើចេញ និង បើកបញ្ញើ ត្រូវមានតារាងវាយឈ្មោះមន្ត្រីប្រចាំការ និង ទទួលខុសត្រូវ ។

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ

ទូរស័ព្ទ: (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០

ទូរសារ: (៨៥៥) ២៣-៤២៦៩៨២/៤២៦០១១

បន្ថែមពីលើការងារជំនាញដូចពោលខាងលើ មន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍គ្រប់ៗរូបត្រូវតែចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនិងចរាចរចេញ-ចូល ឬឆ្លងកាត់នូវគ្រឿងញៀនផ្សេង ៗ ដូចជាផ្តល់ពត៌មានដល់ស្ថាប័នមានសមត្ថកិច្ចក្នុងពេលដែលខ្លួនបានដឹង ឬ បានឃើញ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងសង្ឃឹមថា **លោកប្រធាននាយកដ្ឋានប្រៃសណីយ៍ លោក-លោកស្រី ប្រធានមន្ទីរ ប.ឧ គ្រប់ខេត្ត-ក្រុង ទាំងអស់** ត្រូវចាត់ចែងផ្សព្វផ្សាយនូវសារាចរណែនាំនេះឱ្យបានជ្រួតជ្រាបដល់មន្ត្រីរាជការ បុគ្គលិក ដែលស្ថិតក្រោមឱវាទដើម្បីចូលរួមអនុវត្តន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត ។៚

*រាជធានីភ្នំពេញ, ថ្ងៃទី 22 ខែ កញ្ញា ឆ្នាំ ២០០៤*

**រ ដ្ឋ ម ន្ត្រី**

**សូ ខុន**

***<u>កន្លែងទទួល</u> :***

- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង មហាផ្ទៃ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

  *" <u>ដើម្បីជូនជ្រាប</u> "*

- *ទីចាត់ការគយ និង រដ្ឋាករ*
- *ការិយាល័យ គយ និង រដ្ឋាករប្រៃសណីយ៍*

  *" <u>ដើម្បីជួយសហការអនុវត្តន៍</u> "*

- *នាយកដ្ឋានប្រៃសណីយ៍*
- *អធិការដ្ឋាន*
- *គ្រប់មន្ទីរ ប.ទ ខេត្ត-ក្រុង*

  *" <u>ដើម្បីអនុវត្តន៍</u> "*

- *ឯកសារ-កាលប្បវត្តិ.*